# 👩 បងស្រី ❤️

*នេះគឺជាសាច់រឿងរបស់បងស្រីម្នាក់ អំពីដំណើរនៃការទទួលយកប្អូនរបស់ខ្លួនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ដោយផ្ដើមពីការមិនគាំទ្រទាល់តែសោះ រហូតដល់គាំទ្រយ៉ាងពេញទំហឹង ហើយថែមទាំងក្លាយជាបុគ្គលម្នាក់ ក្នុងការធ្វើឱ្យសមាជិកគ្រួសារផ្សេងទៀតទទួលយកប្អូនរបស់ខ្លួនពេញលេញ ។*

មានទីលំនៅស្រុកប៉ាទី ខេត្តតាកែវ ហើយមានបងប្អូនសរុបចំនួន ១២នាក់ **ទិត ហេង** គឺជាបងស្រីទីបីរបស់ **ទិត ហោ** ដែលមានភេទកំណត់ជាស្ត្រី ហើយបានកំណត់ខ្លួនជាអ្នកប្តូរយេនឌ័រជាបុរស។ ខណៈពេលអង្គុយសំណេះសំណាលលេងជាមួយក្រុមការងាររសេហាគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) នៅលើគ្រែក្រោមផ្ទះ ប្រក់ជញ្ជាំងស្លឹកត្នោត និងដំបូលស័ង្កសី **ទិត ហេង** បានជំណាលថា៖ ដើមឡើយ ខ្ញុំមិនគាំទ្រប្អូនរបស់ខ្ញុំដាច់ខាតដែល ទៅធ្វើបែបនេះ ព្រោះខ្ញុំមិនដែលឃើញមានអ្នកណាទៅឆ្កួតស្រឡាញ់ស្រីនិងស្រីដូចគ្នានោះទេ ម្យ៉ាងទៀតខ្លាចប្អូនគ្មានកូនគ្មានចៅ និងគ្មានអនាគត។ ខ្ញុំតែងតែខំប្រឹងទាញប្អូនឱ្យមកយកប្តីជាមនុស្សប្រុសវិញ ទាន់ខ្លួននៅក្មេង ក្រែងមានកូនម្នាក់ ឬពីរនាក់ ហើយអាចនឹងមានគ្រួសារពេញលេញមួយដូចជាខ្ញុំដែរ។

ខ្ញុំមានកូនបីនាក់ - ស្រីពីរ ប្រុសមួយ។ កូនស្រីច្បងរបស់ខ្ញុំរៀននៅសាកលវិទ្យាល័យផ្នែកវេជ្ជសាស្ត្របានពន្យល់ខ្ញុំថា *«ម៉ាក់! ការស្រឡាញ់ភេទដូចគ្នា គឺជាធម្មជាតិ និងអារម្មណ៍ស្រឡាញ់ដែលមិនអាចហាមឃាត់បាន! ម៉ាក់សាកគិតបន្តិចទៅមើលថា កាលពីដំបូងតើម៉ាក់ស្រឡាញ់ប៉ាយ៉ាងម៉េច នោះអ៊ុ (ទិត ហោ) គឺមានអារម្មណ៍ស្រឡាញ់មនុស្សស្រីដូច្នោះដែរ! បើម៉ាក់សាកឱ្យប៉ាទៅស្រឡាញ់បុរសដូចគ្នា តើអាចទៅរួចទេ? ដូច្នេះម៉ាក់គួរតែយល់ពីចិត្តអ៊ុ ហើយកុំបង្ខំគាត់ទៀតអី។»*



ក្រោយពីបានស្តាប់កូនពន្យល់ ខ្ញុំបានចាប់ផ្តើមគិត ហើយបើកចិត្តទទួលយកប្អូនបន្តិចម្តងៗ ព្រោះម្តាយ និងបងប្អូនឯទៀតរបស់ខ្ញុំក៏បានបើកចិត្តទទួលយកប្អូនរបស់ខ្ញុំខ្លះដែរ។

មូលហេតុផ្សេងទៀតគឺ ខ្ញុំឃើញប្អូនរបស់ខ្ញុំ និងដៃគូរបស់គេចេះស្រឡាញ់ មើលថែគ្នា ហើយមិនបោះបង់គ្នាពេលមានភាពលំបាក ឬបញ្ហាអ្វីក៏ដោយ ជាពិសេសពួកគេទាំងពីរនាក់ខិតខំធ្វើការ ចេះទុកដាក់លុយកាក់ និងចេះសន្សំទ្រព្យទៀតផង ដែលធ្វើឱ្យខ្ញុំមើលឃើញថា នេះពិតជាក្តីស្រឡាញ់ និងក្តីសុខពិតប្រាកដរបស់គូស្រករ។ ប្រពន្ធរបស់ប្អូនខ្ញុំជាស្ត្រីមេម៉ាយកូនពីរ ជាមនុស្សល្អ ចេះគួរសម ដឹងពីសុខទុក្ខគ្រួសារសាច់ញាតិបងប្អូន ជាពិសេសមើលថែ និងស្រឡាញ់ប្អូនខ្ញុំ ដោយចិត្តស្មោះ។



កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ ខ្ញុំបានទៅចូលរួមកម្មវិធី «**សាមគ្គីភាពដើម្បីក្តីស្រឡាញ់**» របស់សហគមន៍ឥន្ទធនូកម្ពុជា ក្នុងសណ្ឋាគារដ៏ធំមួយនៅរាជធានីភ្នំពេញ គឺជាលើកដំបូងដែលខ្ញុំមានឱកាសបានចូលរួមកម្មវិធីដ៏អធិកអធម មានអ្នកមុខអ្នកការ តារាបុរាណសម័យយ៉ាងកុះករបែបនេះ។ ខ្ញុំបានឃើញសមាជិកសហគមន៍របស់ប្អូនខ្ញុំ មានគ្នាច្រើនណាស់ មកពីបណ្តាខេត្តក្រុងជាច្រើន ហើយដៃគូអ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀត ចេះស្រឡាញ់គ្នា យកចិត្តទុកដាក់ និងមើលថែគ្នាបានយ៉ាងផ្អែមល្ហែម។




ក្រោយត្រឡប់មកផ្ទះវិញ ខ្ញុំបានចោទសំណួរសួរខ្លួនឯងថា ***«តើខ្ញុំជាអ្នកណាគេបានជាមិនគាំទ្រប្អូនខ្លួនឯង?»*** សំណួរនេះបានផុសចេញមកនៅពេលខ្ញុំបាន ឮនូវការចែករំលែករបស់អ្នកចម្រៀងមានឈ្មោះបោះសំឡេង ដ៏ល្បីល្បាញលំដាប់ខ្ពស់ នៃប្រទេសខ្មែរយើងម្នាក់ នោះគឺបង **ខាត់ សុឃីម** ដែលគាត់បានទទួលយកប្អូនស្រីដែលស្រឡាញ់មនុស្សស្រីដូចគ្នា ដោយការយល់ចិត្ត និងក្តីស្រឡាញ់ក្នុងនាមជាបងស្រីប្រៀបដូចជាម្តាយម្នាក់ដែរ ហើយខ្ញុំពិតជាស្ងើចសរសើរចំពោះទឹកចិត្តរបស់គាត់ខ្លាំងណាស់។ ***«ចុះចំណែករូបខ្ញុំវិញ តើខ្ញុំជាអ្នកណាគេ បានជាមិនព្រមបើកចិត្តទទួលយកប្អូនរបស់ខ្លួនឯងឱ្យបាន១០០ភាគរយ ដូចគាត់?»***







ខ្ញុំក៏មានភាពស្ញប់ស្ញែងចំពោះក្តីស្រឡាញ់ដ៏ស្មោះស្ម័គ្រ និងការតស៊ូស្វិតស្វាញរបស់អ្នកស្រឡាញ់ភេទដូចគ្នាខ្លាំងណាស់ដែរជាពិសេសប្អូនរបស់ខ្ញុំផ្ទាល់។ ហេតុផលទាំងអស់នេះបានធ្វើឱ្យខ្ញុំភ្លឺភ្នែក គិតពិចារណាបន្ថែម រហូតដល់ឈប់ប្រកាន់ខឹង ឈប់ហាមឃាត់ ហើយក៏ឈប់បារម្ភពីប្អូនហួសហេតុពេក។ **ខ្ញុំក៏ព្រមទទួលយក** ប្អូនរបស់ខ្ញុំ និងប្រពន្ធរបស់គេពេញលេញដោយគ្មានភាពស្ទាក់ស្ទើរតទៅទៀតឡើយ។ ព្រោះតែរឿងរ៉ាវដ៏អស្ចារ្យទាំងនេះ បានធ្វើឱ្យខ្ញុំតាំងចិត្តចង់ជួយពាំនាំរឿងរ៉ាវល្អៗទៅប្រាប់អ្នកជុំវិញខ្លួន ហើយចង់ឱ្យក្រុមគ្រួសាររបស់ខ្ញុំទាំងអស់ទទួលយក ហោ ឱ្យអស់ពីចិត្តថ្លើម និងបេះដូងដូចជារូបខ្ញុំដែរ។ ខ្ញុំយល់យ៉ាងច្បាស់ថា ក្តីស្រឡាញ់ ការយល់ចិត្ត និងការគាំទ្រពីឪពុកម្តាយ ក៏ដូចជាក្រុមគ្រួសារពិតជាសំខាន់ណាស់ ដែលអាចផ្តល់កម្លាំងចិត្ត ជំនឿចិត្ត និងភាពក្លាហានដល់កូន បងប្អូន ឬសាច់ញាតិជាអ្នកស្រឡាញ់ភេទដូចគ្នា ដូចជាករណីខ្ញុំ និងប្អូនរបស់ខ្ញុំ ផ្ទាល់។ ខ្ញុំនឹងនៅក្បែរប្អូន និងប្អូនថ្លៃរបស់ខ្ញុំជានិច្ច មិនឱ្យពួកគេភ័យខ្លាច ហើយឯកោឯកាតទៅទៀតនោះទេ៕

##